www.kidworship.kr

# ចំណងជើង៖ នំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយ



42Page

| | |
|---|---|
| Narration | នៅថ្ងៃមួយព្រះយេស៊ូបានអធិប្បាយព្រះបន្ទូលនៅឯនាយសមុទ្រកាលីឡេ។ពេលនោះមានហ្វូងមនុស្សយ៉ាងច្រើនកុះករបានដើរតាមទ្រង់ ពីព្រោះពួកគេចង់ស្តាប់ និងចង់ឃើញពីការអស្ចារ្យដែលទ្រង់បានសម្តែង។<br>ដោយសារទ្រង់បានដើរកាត់ហ្វូងមនុស្សទាំងអស់នោះ ដូច្នេះទ្រង់បានឮនូវភាពឈឺចាប់ដែលពួកគេបាននិយាយ<br>ដូច្នេះហើយទ្រង់ក៏បានមានព្រះបន្ទូលអំពីស្ថានបរមសុខ។លុះពេលល្ងាចបានមកដល់ពួកសិស្សក៏បានចូលមកឯព្រះយេស៊ូហើយក៏ទូលទៅព្រះអង្គថា៖ |
| សិស្សទី១ | តើយើងគួរធ្វើយ៉ាងណាចំពោះមនុស្សទាំងអស់នេះ លោកគ្រូ? |
| សិស្សទី២ | ទីនេះគឺជាទីកន្លែងដាច់ស្រយាលណាស់ ហើយមេឃក៏ចាប់ផ្តើមងងឹតហើយ។<br>ហេតុអ្វីក៏ពួកយើងមិនឲ្យពួកគេត្រឡប់ទៅឯភូមិ<br>ដើម្បីឲ្យពួកគេបានទិញអាហាររៀងៗខ្លួនទៅ? |
| Narration | ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ |
| ព្រះយេស៊ូ | ពួកគេមិនត្រូវការទៅណាឆ្ងាយទេ! យើងនឹងឲ្យអាហារសំរាប់ពួកគេបានបរិភោគ។ |
| សិស្សទី១ | ព្រះយេស៊ូ! តែពួកយើងគ្មានប្រាក់ទេ!! ទោះបីជាពួកយើងមានប្រាក់<br>ក៏ពួកយើងមិនដឹងថាត្រូវទៅទិញនំប៉័ងនៅឯណាដែរ<br>សំរាប់ឲ្យមនុស្សទាំងអស់នេះបានបរិភោគ?<br>នៅទីនេះគឺគ្មានកន្លែងសំរាប់ទិញអាហារនោះទេ តើយើងត្រូវធ្វើដូចម្តេច<br>ទើបធ្វើឲ្យពួកគេបានឆ្អែតបាន? |
| ព្រះយេស៊ូ | ឆាប់ចេញទៅមើលក្នុងចំណោមហ្វូងមនុស្ស តើមាននរណាមានអ្វីសំរាប់បរិភោគដែរឬទេ? |



43Page

| | |
|---|---|
| Narration | ពួកសិស្សរបស់ទ្រង់បានចេញទៅស្វែងរកក្នុងចំណោមហ្វូងមនុស្ស<br>ហើយពួកគេក៏បានត្រឡប់មកវិញ រួចទូលព្រះយេស៊ូថា៖ |
| សិស្សទី២ | នៅទីនេះគឺមានក្មេងប្រុសម្នាក់ដែលមាននំប៉័ងប្រាំដុំតូច និងត្រីពីរកន្ទុយ។ |
| ព្រះយេស៊ូ | សុំយកអាហារនោះ មកឲ្យខ្ញុំមក។ |
| Narration | ពួកសិស្សក៏បានសុំអាហារពីក្មេងប្រុសនោះ។ |
| សិស្សទី២ | តើអ្នកអាចផ្តល់អាហាររបស់អ្នកទៅព្រះយេស៊ូបានដែរ ឬទេ? |
| ក្មេងប្រុស | បាទ! បាន គឺនៅទីនេះ។ |
| Narration | ក្មេងប្រុសនោះបានឲ្យនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយទៅកាន់ពួកសិស្ស។ |



44Page

**Narration** ពួកសិស្សបានឲ្យអាហារនោះទៅកាន់ព្រះយេស៊ូ។
ព្រះយេស៊ូបានប្រាប់ដល់ហ្វូងមនុស្សទាំងអស់បានអង្គុយជាក្រុម ក្នុងមួយក្រុមអង្គុយ
ហាសិបនាក់ ។ពេលគ្រប់គ្នាបានអង្គុយចុះហើយ
មនុស្សទាំងអស់មានប្រមាណប្រហែលជា ប្រាំរយនាក់
ដោយរាប់តែមនុស្សពេញវ័យប៉ុណ្ណោះ។ ព្រះយេស៊ូបានយកនំបុ័ង និងត្រីពីរកន្ទុយ
អរព្រះគុណដ៏ព្រះជាម្ចាស់ ហើយទ្រង់មានព្រះបន្ទូលថា៖

**ព្រះយេស៊ូ** សូមចែកចាយអាហារទាំងនេះទៅកាន់ពួកគេចុះ។

**Narration** តើមានរឿងហេតុអស្ចារ្យអ្វីបានកើតនៅពេលបន្ទាប់!!
គឺទោះបីជាពួកគេខំប្រឹងចែកចាយយ៉ាងណាក៏ដោយក៏នំបុ័ង
ហើយនិងត្រីគឺមិនបានថយចុះទាល់តែសោះ។

---



45Page

**Narration** មនុស្សប្រាំរយនាក់បានបរិភោគយ៉ាងឆ្អែតឆ្អន់។
គ្រប់គ្នាពិតជាស្ងើចសរសើរអំពីការអស្ចារ្យរបស់ព្រះយេស៊ូ និងអំណាចចេស្តារបស់ទ្រង់
ហើយព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ម្តងទៀតថា៖

**ព្រះយេស** ចូរអ្នកឆាប់ទៅប្រមូលចំណិតអាហារដែលនៅសល់។ សូមកុំឲ្យមានការខ្ជះខ្ជាយឡើយ។

**ពួកសិស្ស** សូមគ្រប់គ្នាបានប្រមូលចំណិតអាហារដែលនៅសល់មកដាក់នៅទីនេះ។

---



46Page

**Narration** នៅពេលដែលពួកគេបានប្រមូលចំណិតអាហារដែលនៅសល់រួចហើយ
នោះពួកគេអាចដាក់បានចំនួន ដប់ពីរកន្ត្រក់ពេញ!
នៅពេលដែលហ្វូងមនុស្សហើយនិងពួកសិស្សរបស់ទ្រង់បានឃើញពីការអស្ចារ្យទាំងនេ
៖ ធ្វើឲ្យពួកគេកាន់តែគោរព និងមានជំនឿលើព្រះយេស៊ូកាន់តែខ្លាំងឡើង
ហើយពួកគេក៏បានបន្តដើរតាមទ្រង់។